អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងធុងប្លាស្ទិក**

**ចិត្តចលភាព** ៖ បំណិនចលនាតូច៖ ការហ្វឹកហាត់ បង្កើនកម្លាំង និងសម្របសម្រួលរវាងចលនាសាច់ដុំដៃនិងសាច់ដុំភ្នែក

**វិទ្យាសាស្ត្រ** ៖ បំណិនអនាម័យ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម

**សិក្សាសង្គម** ៖ បំណិនក្នុងសង្គម៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ

គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ

**ភាសាខ្មែរ** ៖ ការប្រើពាក្យតាមវេយ្យាករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ

**<u>គោលបំណង</u>**

**ចិត្តចលភាព** ៖ វិជ្ជាសម្បទា៖
កំណត់ចំណុចគោលដៅនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយឬលេង ល្បែងបានរឹងមាំល្អ។

**វិទ្យាសាស្ត្រ** ៖ បំណិនសម្បទា៖ ចោលសំរាមនៅក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ

**សិក្សាសង្គម** ៖ វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… ដើម្បីបង្កើតជារូបភាពផ្សេងៗបាន។
បំណិនសម្បទា៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម និងមិនបន្ទោរបង់ផ្តេសផ្តាសជាដើម។

**បុរេគណិត** ៖ វិជ្ជាសម្បទា៖ ប្រាប់បានចំនួនលេខ និងយល់ន័យពីលេខ១ដល់៣០ឬលើសពីនេះ។
បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។

**កម្រិតសិក្សា** ៖ ទាប មធ្យម និងខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កន្ត្រៃ ឧបករណ៍ចោះរន្ធ ខ្សែ ក្រដាសរូបធុងសំរាម កាវស្អិត និងធុងឬក្រឡជ័រធំល្មមមួយ

**ការរៀបចំ** ៖ បង្កើតធុងប្លាស្ទិកមួយឱ្យបានស្អាត និងឱ្យរួចរាល់សម្រាប់បង្ហាញទៅកាន់កុមារមុននឹងឱ្យពួកគេធ្វើទាំងអស់គ្នា។

**សេចក្តីណែនាំ៖**

1. សួរកុមារថា តើសំរាមអាចយកមកប្រើវិញម្តងទៀតបានដែរឬទេ?
2. តើអ្វីខ្លះដែលអាចយកមកកែច្នៃ និងប្រើវាម្តងទៀតបាន?
3. បន្តិចទៀតនេះ គ្រូនឹងនាំអ្នកគ្រប់គ្នាទៅបង្កើត ឬកែច្នៃរបស់ដែលបានប្រើប្រាស់រួច ដើម្បីមកប្រើម្តងទៀតបាន ចង់ឃើញអត់? ចង់ធ្វើដែរអត់?
4. គ្រូបង្ហាញកុមារពីអ្វីដែលបានធ្វើរួចទៅកាន់កុមារទាំងអស់គ្នាជាមុនសិន និងចាប់ផ្តើមប្រាប់ពីរបៀបធ្វើទៅកាន់ពួកគេតែម្តង។
    - ➔ ដំបូង កាត់ក្រដាសធុងសំរាមមួយប្រភេទ រួចបិទនៅលើក្រឡជ័រនោះ
    - ➔ បន្ទាប់មក ប្រើឧបករណ៍ចោះរន្ធ ចោះរន្ធ២ ឱ្យស្មើគ្នា សម្រាប់ដាក់ខ្សែស្ពាយ
    - ➔ បន្ទាប់ពីចោះរួច យកខ្សែមកស៊កចោលក្នុងរន្ធទាំងពីរ និងចង់វាឱ្យបានជាប់ល្អសម្រាប់ស្ពាយជាការស្រេចតែម្តង
    - ➔ ងាយៗ យើងអាចប្រើវាសម្រាប់ដាក់របស់របរសម្ភារផ្សេងបាន ឬសម្រាប់ទុកដើររើសសំរាមក៏បានដែរ។
5. ពេលដែលពួកគេ លេងរួច ឱ្យកុមារជួយប្រមូលរបស់ សម្ភារទុកជាការស្រេចតែម្តង។